ស្ថានទូតអូស្ត្រាលី
ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មានរួម

ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៥

## កម្ពុជាជំរុញអភិបាលកិច្ចធនធានទឹកដែលធន់នឹងការប្រែប្រួលអាកាសធាតុ

*ការពិគ្រោះយោបល់ថ្នាក់ជាតិ ជាជំហានដ៏សំខាន់ក្នុងការរៀបចំផែនទីបង្ហាញផ្លូវរបស់កម្ពុជា សម្រាប់ការគ្រប់គ្រងធនធានទឹកដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងប្រកបដោយបរិយាបន្ន។*

ថ្ងៃនេះ ក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) សហការជាមួយរដ្ឋាភិបាលអូស្ត្រាលី បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីជំរុញការអភិវឌ្ឍ កម្មវិធីអភិបាលកិច្ចធនធានទឹកដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា (CCRWGP)។ កម្មវិធីនេះមានគោលបំណងបង្កើតឡើងនូវយុទ្ធសាស្ត្រធនធានទឹកកម្ពុជា ក្នុងលក្ខណៈនៃការសម្របសម្រួល បរិយាបន្ន និងឆ្លើយតបទៅនឹងហានិភ័យអាកាសធាតុ។

សិក្ខាសាលានេះប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ដែលមានអ្នកចូលរួមជាង ១៧០ នាក់ រួមមានតំណាងជាន់ខ្ពស់មកពីក្រសួងនានា ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ស្ថាប័នស្រាវជ្រាវ និងវិស័យឯកជន។ សិក្ខាសាលានេះជាព្រឹត្តិការណ៍សំខាន់មួយក្នុងការរៀបចំផែនទីបង្ហាញផ្លូវកម្រិតខ្ពស់ សម្រាប់អភិបាលកិច្ចធនធានទឹក ដែលឆ្លុះបញ្ចាំងពីអាទិភាពអភិវឌ្ឍន៍ជាតិ ព្រមទាំងដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលកំពុងកើនឡើង។

ថ្លែងក្នុងពិធីនោះ ឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម បញ្ជាក់ពីភាពបន្ទាន់ក្នុងការចាត់វិធានការលើការគ្រប់គ្រងធនធានទឹក។

"គោលដៅអភិវឌ្ឍន៍របស់កម្ពុជា អាស្រ័យលើសមត្ថភាពរបស់យើង ក្នុងការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាព និងសមភាព។ CCRWGP នឹងផ្តល់នូវក្របខ័ណ្ឌទំនើបកម្ម និងទូលំទូលាយ ដែលជួយនាំផ្លូវអភិបាលកិច្ចធនធានទឹក ការធ្វើផែនការប្រកបដោយបរិយាបន្ន និងឆ្លើយតបទៅនឹងហានិភ័យការប្រែប្រួលអាកាសធាតុដែលគំរាមកំហែងដល់អាយុជីវិត ជីវភាពរស់នៅ និងវឌ្ឍនភាពជាតិ។"

CCRWGP បង្កើតឡើងផ្អែកលើយុទ្ធសាស្ត្របញ្ចកោណរបស់កម្ពុជា និងគាំទ្រដល់គោលដៅនៃការសម្រេចបាននូវគោលដៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសដែលមានចំណូល

ខ្ពស់នៅឆ្នាំ២០៥០។ ជាមួយនឹងការកើនឡើងនៃតម្រូវការទឹក ការផ្លាស់ប្តូរលំនាំទឹកភ្លៀង ព្រមទាំងទឹកជំនន់និងគ្រោះរាំងស្ងួតញឹកញាប់ជាងមុន កម្មវិធីនេះឆ្លើយតបបន្ទាន់ទៅនឹងចន្លោះប្រហោងនៃអភិបាលកិច្ចធនធានទឹក ព្រមទាំងអនុលោមតាមកម្មវិធីដែលកំពុងដំណើរការ និងធ្វើឡើងនាពេលអនាគត។

ឯកឧត្តម ដេវិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ថា CCRWGP ស្របតាមអាទិភាពនៃការអភិវឌ្ឍន៍របស់អូស្ត្រាលីនៅកម្ពុជា ដោយគាំទ្រដល់កំណែទម្រង់ស្ថាប័ន ភាពជាអ្នកដឹកនាំក្នុងតំបន់ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ តាមរយៈភាពជាដៃគូដែលមានបរិយាបន្ន។

ឯកឧត្តម បានបន្ថែមថា "អូស្ត្រាលីមានមោទនភាពដែលបានធ្វើជាដៃគូជាមួយប្រទេសកម្ពុជា លើកម្មវិធីដែលផ្តោតជាចម្បងលើ ភាពធន់នឹងការប្រែប្រួលអាកាសធាតុ អភិបាលកិច្ចប្រកបដោយបរិយាបន្ន និងភាពជាអ្នកដឹកនាំក្នុងតំបន់។ គំនិតផ្តួចផ្តើមនេះឆ្លុះបញ្ចាំងពីអាទិភាពរួមគ្នារបស់យើង និងពង្រឹងសមត្ថភាពរបស់កម្ពុជាក្នុងការដឹកនាំការគ្រប់គ្រងធនធានទឹក តាមរយៈវិធីសាស្ត្រជាក់ស្តែង និងមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ។"

ផែនទីបង្ហាញផ្លូវសម្រាប់អភិបាលកិច្ចធនធានទឹកដែលធន់នឹងការប្រែប្រួលអាកាសធាតុនេះ ត្រូវបានបង្កើតឡើងតាមរយៈការពិគ្រោះយោបល់ទូលំទូលាយ កាលពីខែឧសភា ឆ្នាំ២០២៥ រួមមានសសរស្តម្ភយុទ្ធសាស្ត្រចំនួនបួន៖ ការធ្វើទំនើបកម្មច្បាប់ជាតិស្តីពីធនធានទឹក ការកសាងសមត្ថភាពនិងការលើកកម្ពស់ការចូលរួមប្រកបដោយបរិយាបន្ន ការកែលម្អទិន្នន័យ ប្រព័ន្ធ និងការគ្រប់គ្រងហានិភ័យ ព្រមទាំងអនុវត្តការសាកល្បងនិងសិក្សា។ ផែនការនេះត្រូវបានបង្កើតឡើងជាក្របខ័ណ្ឌកម្រិតខ្ពស់ដែលមានភាពបត់បែន ដើម្បីដឹកនាំសកម្មភាពសម្របសម្រួលនៅទូទាំងស្ថាប័នរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសហគមន៍។

សិក្ខាសាលាថ្ងៃនេះបានបញ្ចូលមតិកែលម្អលើការអភិវឌ្ឍកម្មវិធី ដោយភាគីពាក់ព័ន្ធបានគាំទ្រយ៉ាងទូលំទូលាយនូវផែនទីបង្ហាញផ្លូវ និងផ្តល់អនុសាសន៍តាមគោលដៅ រួមមានការពង្រឹងការសម្របសម្រួលអន្តរក្រសួង ការពន្លឿនកំណែទម្រង់ច្បាប់និងគោលនយោបាយ ព្រមទាំងការសាកល្បងគំរូអភិបាលកិច្ចធនធានទឹករួមបញ្ចូលគ្នានៅថ្នាក់ក្រោមជាតិ។

ការពិគ្រោះយោបល់នេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរួមគ្នាចំពោះការបង្កើតគោលនយោបាយដែលមានបរិយាបន្ន និងភាពជាម្ចាស់របស់ប្រទេស។ ឥឡូវនេះ MoWRAM នឹងបញ្ចូលមតិកែលម្អដែលប្រមូលបាន ទៅក្នុងការអភិវឌ្ឍបង្កើតកម្មវិធី ដោយការអនុវត្តដំណាក់កាលទី១ រំពឹងថានឹងចាប់ផ្តើមនៅចុងឆ្នាំនេះ។

នៅពេលដែលវិបត្តិអាកាសធាតុកាន់តែស៊ីជម្រៅ កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការដឹកនាំជាមួយនឹងអភិបាលកិច្ចធនធានទឹកដែលផ្អែកលើភស្តុតាង បរិយាបន្ន និងឆ្ពោះទៅមុខ ផ្តល់នូវផ្លូវដ៏សំខាន់មួយទៅកាន់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់


- ក្រសួងធនធានទឹក និងឧតុនិយម (MoWRAM): tesamedy@gmail.com
- ស្ថានទូតអូស្ត្រាលី: Media.Cambodia@dfat.gov.au